01064358

លេខ / N°: D122

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ឯកសារទទួល
ORIGINAL/ORIGINAL DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 11 / 02 / 2015
ម៉ោង (Time/Heure): 15:50
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Sann Rada

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia

ការិយាល័យសហចៅក្រមស៊ើបអង្កេត
Office of the Co-Investigating Judges
Bureau des Co-juges d'instruction

សំណុំរឿងព្រហ្មទណ្ឌ
Criminal Case File /Dossier pénal
លេខ/No:003/07-09-2009-ECCC-OCIJ

# កំណត់ហេតុនៃការចូលខ្លួនដំបូង
# Written Record of Initial Appearance
# Procès-Verbal d'Interrogatoire de Première Comparution

នៅថ្ងៃទី ប្រាំបី ខែ ធ្នូ ឆ្នាំ ពីរពាន់ដប់បួន ម៉ោង មួយ ដប់បីនាទី រសៀល

ខ្ញុំ **Mark B. Harmon** សហចៅក្រមស៊ើបអង្កេតអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជាមួយនឹង លី ច័ន្ទតុលា ជា ក្រឡាបញ្ជី

**បានឃើញ** ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ ("ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក")។

**បានឃើញ** វិធាន ២១,២២,២៥, ៥៥, ៥៧, ៦៣(១) និង៧២ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("វិធានផ្ទៃក្នុង")។

**បានឃើញ** *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី២ របស់សហព្រះរាជអាជ្ញាទាក់ទងនឹងកងទ័ពបដិវត្តន៍កម្ពុជា* ដាក់នៅថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩[1]។

---

[1] សំណុំរឿង ០០៣ ឯកសារ D1 *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី២របស់សហព្រះរាជអាជ្ញា ទាក់ទងនឹងកងទ័ពបដិវត្តន៍កម្ពុជា* ដាក់នៅថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩។

**បានឃើញ** *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាស្តីពីទីតាំងឧក្រិដ្ឋកម្មនានាទាក់ទងនឹងសំណុំរឿង ០០៣* ដាក់នៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤("ដីកាសន្និដ្ឋានបញ្ជូនឱ្យស៊ើបសួរបន្ថែម"[2]។

**បានឃើញ** កិច្ចស៊ើបសួរទាក់ទងនឹងការចោទប្រកាន់អំពីការរំលោភបំពាន**ក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** និង**អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩** ជាបទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៣(ថ្មី), ៥, ៦, ២៩ និង ៣៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងមាត្រា៥០០, ៥០១, ៥០៣, ៥០៥, ៥០៦, ៥០៧ និង ៥០៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦។

**បានឃើញ**កំណត់ហេតុនៃករណីខ្វែងយោបល់គ្នា ចុះបញ្ជីនៅថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៤។

**បានឃើញ**ថា ខ្ញុំបានកោះហៅមាស មុត ឱ្យមកបង្ហាញខ្លួននៅចំពោះមុខខ្ញុំ នៅថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០១៤ ម៉ោង ១ រសៀល នៅ អ.វ.ត.ក ដែលមានទីតាំងនៅផ្លូវជាតិ ៤ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ ភ្នំពេញ សម្រាប់ការបង្ហាញខ្លួនលើកដំបូង[3]។

**បានឃើញ**ថា ដីកាកោះនេះបានប្រគល់ជូនគាត់ ដោយផ្ទាល់នៅថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៤ នៅលំនៅដ្ឋានរបស់គាត់។

**បានឃើញ**ថា សហមេធាវីរបស់ មាស មុត គឺលោក អាង ឧត្តម និងលោក Michael G. Karnavas ត្រូវបានកោះហៅឱ្យចូលរួមការបង្ហាញខ្លួនលើកដំបូងរបស់កូនក្តី[4]។

**បានឃើញ**ថា នៅថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១៤ ខ្ញុំ បានលើកលែងលោក Michael G. Karnavas មិនចាំបាច់ចូលរួមការបង្ហាញខ្លួនលើកដំបូងដែលបានគ្រោងទុកនេះទេ ហើយបានអនុញ្ញាតឱ្យអ្នកស្រី Tanya Pettay ចូលរួម។

---

[2]សំណុំរឿង ០០៣ ឯកសារ D120 *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីពីទីតាំងឧក្រិដ្ឋកម្មនានាទាក់ទងនឹងសំណុំរឿង ០០៣* ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤។

[3]សំណុំរឿង០០៣ ឯកសារA66 *ដីកាកោះហៅមាស មុត ឱ្យបង្ហាញខ្លួនលើកដំបូង* ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៤។

[4]សំណុំរឿង០០៣ ឯកសារ A67 *ដីកាកោះហៅសហមេធាវីរបស់មាស មុត ឱ្យចូលរួមការបង្ហាញខ្លួនលើកដំបូងរបស់មាស មុត* ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៤។

ដោយមានវត្តមានរបស់លោក អាង ឧត្តម សហមេធាវីជាតិ អ្នកស្រី Tanya Pettay អ្នកប្រឹក្សាច្បាប់ជាន់ខ្ពស់ និងអ្នកស្រី ម៉ាង ម៉ូនីកា អ្នកគ្រប់គ្រងសំណុំរឿង។

ដោយមានវត្តមានរបស់លោក អ៊ួក វរ៉ា អ្នកបកប្រែភាសាដែលបានស្បថនៅ អ.វ.ត.ក។

ដោយមានវត្តមានរបស់លោក ឃ្លោក សួសសូឡាលីន ជំនួយការបច្ចេកទេសនៅ អ.វ.ត.ក។

បានរៀបចំការបង្ហាញខ្លួនលើកដំបូងរបស់ មាស មុត នៅ អ.វ.ត.ក។

ខ្ញុំបានជូនដំណឹងសហមេធាវីជាតិ អាង ឧត្តម អ្នកស្រី Tanya Pettay អ្នកប្រឹក្សាច្បាប់ជាន់ខ្ពស់ និងអ្នកស្រី ម៉ាង ម៉ូនីកា អ្នកគ្រប់គ្រងសំណុំរឿង ថា ការបង្ហាញខ្លួនលើកដំបូងនេះនឹងត្រូវថតយកសម្លេង/វីដេអូ។

កំណត់ហេតុនេះធ្វើឡើងជាភាសាអង់គ្លេសតាមសំណើរបស់សហមេធាវីជាតិ អាង ឧត្តម និង អ្នកស្រី Tanya Pettay អ្នកប្រឹក្សាច្បាប់ជាន់ខ្ពស់។

**សំណួរសួរដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ("ស.ច.ស.អ")៖** តើលោក មាស មុត មានវត្តមាននៅក្នុងការបង្ហាញខ្លួនលើកដំបូងនេះទេ?

**ចម្លើយផ្តល់ដោយសហមេធាវី៖** ទាក់ទងនឹងរឿងនេះ លោក មាស មុត មានគោលជំហរដូចបានបញ្ជាក់នៅក្នុងលិខិតរបស់គាត់ដែលបានផ្ញើជូនតុលាការនេះហើយ៖ សេចក្តីជូនដំណឹងចុះថ្ងៃទី ២ ខែធ្នូ ឆ្នាំ ២០១៤ ស្តីពីការមិនទទួលស្គាល់ដីកាកោះ។

**សំណួរសួរដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ("ស.ច.ស.អ")៖** តើ លោក បានទទួលលិខិតមួយច្បាប់ពីខ្ញុំចុះថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០១៤ ទាក់ទងនឹងការពន្យល់របស់ខ្ញុំអំពីច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ទាក់ទងនឹងដីកាកោះដែលចេញដោយ ស.ច.ស តែម្នាក់ឯង ដែរឬទេ?

**ចម្លើយផ្តល់ដោយសហមេធាវី៖** បាទ។

**សំណួរសួរដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ("ស.ច.ស.អ")៖**ទោះបីជាមានខ្លឹមសារលិខិតចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៤ ដែលបានផ្ញើជូនលោក និងលោក Karnavas យ៉ាងណាក៏ដោយ ក៏លោក មាស មុត បានសម្រេចចិត្តមិនចូលបង្ហាញខ្លួននៅថ្ងៃនេះសម្រាប់កិច្ចដំណើរការនីតិវិធីទាំងនេះទេ។ តើខ្ញុំត្រូវទេ?

**ចម្លើយផ្តល់ដោយសហមេធាវី៖** បាទ។ លោកចៅក្រម ត្រូវ។

**សម្រាប់ទុកជាកំណត់ហេតុ ស.ច.ស.អ** បានកត់សម្គាល់ថា លោក មាស មុត មិនបានមកបង្ហាញខ្លួនសម្រាប់ការបង្ហាញខ្លួនលើកដំបូងរបស់គាត់ទេ។

**សំណួរសួរដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ("ស.ច.ស.អ")៖** តើលោកមានអ្វីចង់បញ្ចេញយោបល់ទេ?

**ចម្លើយផ្តល់ដោយសហមេធាវី៖** ខ្ញុំមានសំណើមួយ និងសំណួរមួយ។

ឥឡូវនេះ ខ្ញុំសូមធ្វើសំណើដោយផ្ទាល់មាត់ ទោះបីជាខ្ញុំបានស្នើដដែលៗលើបញ្ហានេះក៏ដោយ គឺខ្ញុំស្នើឡើងវិញអំពីសំណើរបស់ខ្ញុំសុំចូលពិនិត្យសំណុំរឿងដែលប្រឆាំងកូនក្តីខ្ញុំ។

**ចម្លើយផ្តល់ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ("ស.ច.ស.អ")៖** សំណើរបស់លោកសុំចូលពិនិត្យមើលសំណុំរឿង ត្រូវបានបដិសេធ។ មូលហេតុដែល ស.ច.ស នៅទីនេះតែម្នាក់ឯង គឺជាការសម្ងាត់។

**យោបល់ផ្តល់ដោយសហមេធាវីជាតិ៖** ការណ៍ដែលមិនអនុញ្ញាតឱ្យចូលពិនិត្យមើលសំណុំរឿងតាំងពីដំបូង រហូតដល់ពេលឥឡូវនេះ គឺជាការរំលោភបំពានសិទ្ធិកូនក្តីខ្ញុំ ហើយខ្ញុំគិតថា វាមិនមានប្រយោជន៍ទេដែលត្រូវបដិសេធមិនអនុញ្ញាតឱ្យគាត់ចូលពិនិត្យមើលសំណុំរឿងនោះ ប៉ុន្តែ វានឹងបង្កើតឱ្យមានបញ្ហាសម្រាប់ពេលអនាគត។ ខ្ញុំមិនមានយោបល់បន្ថែមទៀតទេ។

**ចម្លើយតបផ្តល់ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ("ស.ច.ស.អ")៖** យោបល់របស់លោកត្រូវបានកត់សម្គាល់។

**សំណួរសួរដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ("ស.ច.ស.អ")៖** ប្រសិនបើលោកមិនមានយោបល់បន្ថែមទៀតទេ ខ្ញុំនឹងបញ្ចប់កិច្ចដំណើរការបង្ហាញខ្លួនលើកដំបូងនេះហើយ។

**ចម្លើយផ្តល់ដោយសហមេធាវី៖** មិនមានទេ លោក។

សវនាការបង្ហាញខ្លួនលើកដំបូងនេះ បានចប់នៅម៉ោង មួយ សាមសិបប្រាំពីរនាទី រសៀល នៅថ្ងៃដដែលនោះ។

**លេខ៖ D122**

សំណៅថតចម្លងមួយច្បាប់នៃកំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងនេះ ត្រូវបានផ្តល់ជូនសហមេធាវីជាតិ។

| | | |
|---|---|---|
| **ចៅក្រម Mark B. Harmon**<br>**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**<br><br>*ហត្ថលេខា*<br>*កាលបរិច្ឆេទ៖ ០៨/១២/២០១៤* | **លី ចន្ទតុលា**<br>**ក្រឡាបញ្ជី**<br><br>*ហត្ថលេខា*<br>*កាលបរិច្ឆេទ៖ ០៨/១២/២០១៤* | **អ្នកបកប្រែភាសា**<br><br>*ហត្ថលេខា*<br>*កាលបរិច្ឆេទ៖* |
| **មាស មុត**<br>**ជនត្រូវចោទ**<br><br>*ហត្ថលេខា/ស្នាមមេដៃ*<br>*កាលបរិច្ឆេទ៖* | **អាង ឧត្តម**<br>**មេធាវីជាតិរបស់មាស មុត**<br><br>*ហត្ថលេខា*<br>*កាលបរិច្ឆេទ៖ ១១-១២-១៤* | **Tanya Pettay**<br>តំណាងឲ្យលោក **Michael G. Karnavas**<br>**មេធាវីអន្តរជាតិរបស់មាស មុត**<br><br>*ហត្ថលេខា*<br>*កាលបរិច្ឆេទ៖ ១១ ធ្នូ ២០១៤* |